ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION
លេខ...១៧៥៨០.........ព.ម

ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី...១៩.....ខែ...១២.......ឆ្នាំ...២០១៧

# រដ្ឋមន្ត្រីក្រសួងព័ត៌មាន

## ជម្រាបមក

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ស្ថានីយវិទ្យុ-ទូរទស្សន៍ទាំងអស់

**កម្មវត្ថុ**: ហាមចាក់ផ្សាយបទចម្រៀងមានចំណងជើងថា «គ្រូបង្រៀនស្រវឹងស្រា» របស់ក្រុមហ៊ុនផលិតកម្មថោន។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ម្ចាស់ស្ថានីយវិទ្យុ ទូរទស្សន៍ទាំងអស់ ជ្រាបថា បទចម្រៀងរបស់ក្រុមហ៊ុនផលិតកម្មថោន មានចំណងជើងថា«គ្រូបង្រៀនស្រវឹងស្រា» ច្រៀងដោយលោកស្រី ចេន សាយចៃ មានខ្លឹមសារបន្ថុះបង្អាប់ ប្រមាថ គ្រូបង្រៀនថា ផឹកស្រាស្ទើរពេលថ្ងៃ ស្រវឹងទាំងថ្ងៃ វាចាពុំក្លិនតែស្រា ឲ្យតែស្រវឹងកាចចម្លែកបង្រៀនប្លែកៗខឹងស្រែក ខឹងវាយខុសក្រមច្បាប់គ្រូ ដែលខ្លឹមសារនៃបទចម្រៀងនេះបានប្រាសចាកអំពីអកប្បកិរិយា និងសីលធម៌ ថ្លៃថ្នូររបស់គ្រូបង្រៀនទូទៅ ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់គ្រូបង្រៀន ដែលធ្វើឲ្យមានប្រតិកម្មពីសំណាក់មហាជនទូទៅ និង ជះឥទ្ធិពលមិនល្អដល់សង្គមទាំងមូលហើយ សារខ្លឹមសារបទចម្រៀងនេះ បានដក់ជាប់នឹងអារម្មណ៍របស់កុមារតូចៗ ដែលពុំទាន់មានមូលដ្ឋាននៃការពិចារណាច្បាស់លាស់នៅឡើយ។

ដូច្នេះ ដើម្បីចៀសវាងផលអវិជ្ជមាន និងប៉ះពាល់ដល់អារម្មណ៍ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់គ្រូបង្រៀនទូទៅពីការផ្សព្វផ្សាយបទចម្រៀងនេះ ក្រសួងព័ត៌មាន សូមឯកឧត្តម លោកជំទាវ លោក លោកស្រីម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ទាំងអស់ ហាមចាក់ផ្សាយបទចម្រៀងមានចំណងជើងថា «គ្រូបង្រៀនស្រវឹងស្រា» របស់ផលិតកម្មថោនចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់តាមការគួរ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

<u>ចម្លងជូន</u>
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- មន្ទីរព័ត៌មានខេត្ត-រាជធានី
- ស្ថានីយវិទ្យុ ទូរទស្សន៍ទាំងអស់
- សមាគមសិល្បៈករកម្ពុជា
- សមាគមវិទ្យុកម្ពុជា និងសមាគមទូរទស្សន៍កម្ពុជា «ដើម្បីអនុវត្ត»
- ឯកសារ